# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ១៦៤ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីការគ្រប់គ្រងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយនិងប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានមួយទៀតក្នុងវិស័យសាធារណៈ និងជាមួយវិស័យឯកជន ក្នុងក្របខណ្ឌអន្តរប្រតិបត្តិការ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា "**ថ.ផ.ធ.**" (Cambodia Data Exchange "CamDX") ប្រកបដោយសុវត្ថិភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ជំរុញការទទួលយក និងបរិវត្តកម្មឌីជីថលស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការផ្លាស់ប្តូរទិន្នន័យតាមរយៈ **ថ.ផ.ធ.** ក្នុងវិស័យសាធារណៈ ដែលមានជាអាទិ៍ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងវិស័យឯកជនដែលជាសមាជិករបស់ **ថ.ផ.ធ.**។

ការផ្លាស់ប្តូរទិន្នន័យពាក់ព័ន្ធនឹងវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធក្នុងវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ជាធរមាន។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យ ដូចក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## អំពី ថ.ផ.ធ.

**មាត្រា៤.-**

**ថ.ផ.ធ.** ជាថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានបង្កើតឡើងសម្រាប់ផ្លាស់ប្តូរទិន្នន័យ ដោយប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័ររវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌-មានមួយទៀតក្នុងវិស័យសាធារណៈ និងជាមួយវិស័យឯកជនដែលជាសមាជិករបស់ **ថ.ផ.ធ.** ដោយសុវត្ថិភាព តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬបណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ។

គំនូសតាងនៃប្រព័ន្ធអន្តរប្រតិបត្តិការរបស់ **ថ.ផ.ធ.** ត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា៥.-**

ទិន្នន័យដែលត្រូវផ្លាស់ប្ដូរតាមរយៈ **ថ.ផ.ឆ.** ត្រូវបានធ្វើកូដនីយកម្មនិងចុះហត្ថលេខាឌីជីថល ដើម្បីធានាបាននូវសុវត្ថិភាព សុចរិតភាព និងសុក្រឹតភាពនៃទិន្នន័យ ព្រមទាំងត្រូវបានធ្វើកំណត់ត្រាអេឡិចត្រូនិកពីការផ្លាស់ប្ដូរទិន្នន័យ។

**មាត្រា៦.-**

រាល់ការផ្លាស់ប្ដូរទិន្នន័យតាមរយៈ **ថ.ផ.ឆ.** ត្រូវបានធានាថាទិន្នន័យមិនត្រូវបានរក្សាទុក នៅក្នុងប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានរបស់ **ថ.ផ.ឆ.** និង/ឬចែកចាយជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដោយគ្មានការអនុញ្ញាតពីម្ចាស់ទិន្នន័យដើមទេ។

## ជំពូកទី៣

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៧.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "**ក.ស.ហ. វ.**" ជាសេនាធិការជូនរាជរដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំនិងគ្រប់គ្រងលើ **ថ.ផ.ឆ.** សំដៅជំរុញការទទួលយក និងបរិវត្តកម្មឌីជីថលស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨.-**

ប្រតិបត្តិការរបស់ **ថ.ផ.ឆ.** ត្រូវគ្រប់គ្រងដោយប្រតិបត្តិករ **ថ.ផ.ឆ.** ដែលមាន **ក.ស.ហ.វ.** ជាអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ប្រតិបត្តិករ **ថ.ផ.ឆ.** ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែកតាមសំណើរបស់រដ្ឋមន្ត្រី **ក.ស.ហ.វ.**។

## ជំពូកទី៤

## សមាជិកភាព និងភារកិច្ចរបស់សមាជិក

### ផ្នែកទី១

### វិធានរួម

**មាត្រា៩.-**

សមាជិក **ថ.ផ.ឆ.** ត្រូវបានចែកចេញជាពីរប្រភេទ រួមមាន÷

- សមាជិកភាពដោយស្វ័យប្រវត្តិ និង
- សមាជិកភាពដោយការស្នើសុំ។

សមាជិកនីមួយៗ អាចជាអ្នកទទួលទិន្នន័យ និង/ឬជាអ្នកផ្ដល់ទិន្នន័យ។

**មាត្រា១០.-**

សមាជិកភាពដោយស្វ័យប្រវត្តិ ជាវិស័យសាធារណៈ ដែលមានជាអាទិ៍ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

សមាជិកភាពដោយការស្នើសុំ ជាវិស័យឯកជន ដែលមានជាអាទិ៍ ក្រុមហ៊ុន/សហគ្រាសពាណិជ្ជកម្ម សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១១.-**

សមាជិក **ថ.ផ.ទ.** មានភារកិច្ចដូចតទៅ÷

- ផ្លាស់ប្តូរនិងប្រើប្រាស់ទិន្នន័យស្របតាមបែបបទនីតិវិធីដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬអនុស្សរណៈនៃការយោគយល់គ្នាជាមួយ **គ.ស.ហ.ទ.** ឬជាមួយប្រតិបត្តិករ **ថ.ផ.ទ.**
- រៀបចំធ្វើយថាភូតភាពអត្តសញ្ញាណឌីជីថលជាមួយប្រព័ន្ធផ្ទៀងផ្ទាត់អត្តសញ្ញាណរួមរបស់ **ថ.ផ.ទ.** ដើម្បីកំណត់អត្តសញ្ញាណសមាជិកនៅពេលផ្លាស់ប្តូរទិន្នន័យ
- ទទួលខុសត្រូវថែទាំហេដ្ឋារចនាសម្ព័ន្ធបណ្តាញ និងបច្ចេកទេសរបស់ខ្លួន តាមការតម្រូវរបស់ប្រតិបត្តិករ **ថ.ផ.ទ.**
- រាយការណ៍ជូនប្រតិបត្តិកររាល់ភាពមិនប្រក្រតី លើការផ្លាស់ប្តូរទិន្នន័យតាម **ថ.ផ.ទ.** ក្នុងរយៈពេលមិនលើសពី ២៤ (ម្ភៃបួន) ម៉ោង ក្រោយពីបានរាយតម្លៃរួច
- ចងក្រង រក្សាទុករបាយការណ៍ និងឯកសារពាក់ព័ន្ធនឹងការផ្លាស់ប្តូរទិន្នន័យតាមរយៈ **ថ.ផ.ទ.**
- រៀបចំនិងថែរក្សាកំណត់ត្រាបច្ចេកទេសប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន ដើម្បីជាមូលដ្ឋានក្នុងការត្រួតពិនិត្យសន្តិសុខបច្ចេកវិទ្យាព័ត៌មាន
- សហការដោះស្រាយរាល់បញ្ហានានា ពាក់ព័ន្ធនឹងប្រតិបត្តិការ **ថ.ផ.ទ.** ឱ្យបានឆាប់បំផុត និង
- ផ្តល់កិច្ចសហការផ្សេងទៀតតាមការស្នើសុំរបស់ប្រតិបត្តិករ **ថ.ផ.ទ.** និង/ឬ **គ.ស.ហ.ទ.** ទាក់ទងនឹងការផ្លាស់ប្តូរទិន្នន័យតាម **ថ.ផ.ទ.**។

## ផ្នែកទី២

## សមាជិកភាពដោយស្វ័យប្រវត្តិ

**មាត្រា១២.-**

រាល់ការផ្លាស់ប្តូរទិន្នន័យរបស់សមាជិកភាពដោយស្វ័យប្រវត្តិក្នុងក្របខណ្ឌទិន្នន័យគោល ដើម្បីផ្តល់សេវាសាធារណៈ និងក្នុងក្របខណ្ឌអន្តរប្រតិបត្តិការនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវធ្វើឡើងនៅលើ **ថ.ផ.ទ.** តែមួយគត់។

**មាត្រា១៣.-**

សមាជិកភាពដោយស្វ័យប្រវត្តិ ត្រូវសហការនិងសម្របសម្រួលជាមួយប្រតិបត្តិករ **ថ.ផ.ឆ.** ដើម្បីរៀបចំបែបបទនិងនីតិវិធីសម្រាប់ការផ្លាស់ប្តូរទិន្នន័យលើ **ថ.ផ.ឆ.**។

បែបបទនិងនីតិវិធីលម្អិតសម្រាប់សមាជិកភាពដោយស្វ័យប្រវត្តិផ្លាស់ប្តូរទិន្នន័យលើ **ថ.ផ.ឆ.** ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា១៤.-**

សមាជិកភាពដោយស្វ័យប្រវត្តិ មិនអាចបោះបង់សមាជិកភាពទេ វៀរលែងតែក្នុងករណីដែលសមាជិកភាពដោយស្វ័យប្រវត្តិនោះ ត្រូវបានរំលាយចោល ឬត្រូវបានធ្វើសមាហរណកម្មជាមួយស្ថាប័នដទៃ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៣

## សមាជិកភាពដោយការស្នើសុំ

**មាត្រា១៥.-**

ដើម្បីអាចក្លាយជាសមាជិកភាពដោយការស្នើសុំ វិស័យឯកជន ត្រូវបំពេញពាក្យស្នើសុំទៅតាមទម្រង់និងបែបបទដែលកំណត់ដោយប្រតិបត្តិករ **ថ.ផ.ឆ.** និងត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

- ជានីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បំពេញលក្ខខណ្ឌតម្រូវបច្ចេកទេសអប្បបរមា ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យនេះ
- ធានាថារាល់ការទទួលយកនិងផ្លាស់ប្តូរទិន្នន័យមិនផ្តល់ការគំរាមកំហែងដល់សន្តិសុខជាតិ មិនប៉ះពាល់ដល់ភាពស្របច្បាប់នៃផលប្រយោជន៍សាធារណៈ សណ្តាប់ធ្នាប់និងផលប្រយោជន៍សង្គម សិទ្ធិឯកជនរបស់ម្ចាស់ទិន្នន័យ ឬប៉ះពាល់ដល់នយោបាយសាធារណៈរបស់រដ្ឋ និង
- បង់ថ្លៃដាក់ពាក្យស្នើសុំចូលជាសមាជិក។

សំណើសុំចូលជាសមាជិក **ថ.ផ.ឆ.** អាចត្រូវបានបដិសេធ ក្នុងករណីដែលពាក្យស្នើសុំចូលជាសមាជិក ពុំបំពេញតាមលក្ខខណ្ឌដែលបានកំណត់ក្នុងអនុក្រឹត្យនេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បែបបទនិងនីតិវិធីលម្អិតសម្រាប់ចូលជាសមាជិកភាពដោយការស្នើសុំផ្លាស់ប្តូរទិន្នន័យលើ **ថ.ផ.ឆ.** ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា១៦.-**

ដើម្បីក្លាយជាសមាជិកភាពដោយការស្នើសុំ បេក្ខភាពត្រូវបំពេញតាមលក្ខខណ្ឌតម្រូវអប្បបរមា ដូចតទៅ÷

- ត្រូវធានាបានថាទិន្នន័យដែលបានផ្លាស់ប្តូរតាមរយៈ **ថ.ផ.ឆ.** ត្រូវបានប្រើប្រាស់ក្នុងគោលបំណងនៃការធ្វើធុរកិច្ច និងសង្គមកិច្ច ស្របតាមអនុស្សរណៈនៃការយោគយល់គ្នា ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

- ត្រូវធានាបាននូវគុណភាព និងសុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ត្រូវមានហេដ្ឋារចនាសម្ព័ន្ធបណ្ដាញ និងសម្ភារបរិក្ខារបច្ចេកវិទ្យាព័ត៌មានស្នូល ដើម្បីបម្រុងសម្រាប់ប្រតិបត្តិការ ធានានូវសន្តិសុខ សុវត្ថិភាព សុក្រឹតភាព និងគុណភាពប្រព័ន្ធ
- ត្រូវមានលទ្ធភាពដំឡើងម៉ាស៊ីនមេសុវត្ថិភាពក្នុងបណ្ដាញប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន និង
- ត្រូវមានសមត្ថភាពចូលរួមសហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការចាត់វិធានការឆ្លើយតបលើការវាយប្រហារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា១៧.-**

សមាជិកភាពដោយការស្នើសុំ ដែលមានបំណងចង់បោះបង់សមាជិកភាពពី **ថ.ផ.ឆ.** ត្រូវបំពេញនិងបង់ថ្លៃពាក្យស្នើសុំបញ្ចប់សមាជិកភាពពី **ថ.ផ.ឆ.** តាមការកំណត់ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ប្រតិបត្តិករ **ថ.ផ.ឆ.** ត្រូវសម្របសម្រួលនីតិវិធីបោះបង់សមាជិកភាព និងជូនព័ត៌មានទៅកាន់សមាជិកដទៃទៀត ជាពិសេសសមាជិកពាក់ព័ន្ធដែលជាអ្នកទទួលទិន្នន័យ និង/ឬម្ចាស់ទិន្នន័យដើម។

ការបញ្ចប់សមាជិកភាពពី **ថ.ផ.ឆ.** ត្រូវមានប្រសិទ្ធភាព គិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងស្ដីពីការបញ្ចប់សមាជិកភាពជាស្ថាពរ ដែលចេញដោយប្រតិបត្តិករ **ថ.ផ.ឆ.**។

**មាត្រា១៨.-**

ប្រតិបត្តិករ **ថ.ផ.ឆ.** មានសិទ្ធិពេញលេញក្នុងការបញ្ចប់សមាជិកភាពរបស់សមាជិកភាពដោយការស្នើសុំណាមួយក្នុងករណីរកឃើញថាសមាជិកនោះ បានប្រព្រឹត្តមិនប្រក្រតី ឬមិនគោរពតាមគោលការណ៍ ឬលក្ខខណ្ឌដែលមានចែងក្នុងអនុក្រឹត្យនេះ ឬអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រតិបត្តិករ ឬបានប្រព្រឹត្តល្មើសនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥

## ប្រតិបត្តិការតាម ថ.ផ.ឆ.

**មាត្រា១៩.-**

សមាជិក **ថ.ផ.ឆ.** ត្រូវទទួលខុសត្រូវលើបន្ទុកចំណាយប្រតិបត្តិការតភ្ជាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនមកកាន់ **ថ.ផ.ឆ.** ដែលមានជាអាទិ៍ ហេដ្ឋារចនាសម្ព័ន្ធបណ្ដាញ សម្ភារបរិក្ខារអេឡិចត្រូនិក និងធនធានមនុស្ស។

**មាត្រា២០.-**

ការទាញយកទិន្នន័យត្រូវរាប់ជាចំនួនប្រតិបត្តិការ ហើយម្ចាស់ទិន្នន័យដើមអាចកំណត់កម្រៃសេវាក្នុងមួយប្រតិបត្តិការនៃការទាញយកទិន្នន័យពីអ្នកទទួលទិន្នន័យ ទៅតាមប្រភេទនៃទិន្នន័យ។

វិធាននិងនីតិវិធីនៃការកំណត់កម្រៃសេវា ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា២១.-**

កម្រៃសេវាដែលបានមកពីប្រតិបត្តិការតាម **ថ.ផ.ឆ.** និងចំណូលផ្សេងទៀតរបស់ប្រតិបត្តិករ **ថ.ផ.ឆ.** ត្រូវចាត់ទុកជាចំណូលមិនមែនសារពើពន្ធ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

## ជំពូកទី៦

## វិធានការសន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**មាត្រា២២.-**

វិធានការសន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាវិធីសាស្ត្រការពារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពីការវាយប្រហារ ដែលមានជាអាទិ៍÷

- ការលួចយកទិន្នន័យ ការកែប្រែដោយគ្មានការអនុញ្ញាត លើទិន្នន័យមូលដ្ឋានដើម និងទិន្នន័យចរាចរ
- ការព្យាយាម ឬការជ្រៀតចូលតាមគ្រប់រូបភាពទៅក្នុង **ថ.ផ.ឆ.** និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់សមាជិក
- ការព្យាយាម ឬការវាយលុកធ្វើឱ្យរអាក់រអួលដល់ប្រតិបត្តិការ **ថ.ផ.ឆ.** និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់សមាជិក
- ការសមគំនិត ឬការផ្ដល់មធ្យោបាយ ឬការផ្ដល់ជាវិធីសាស្ត្រក្នុងការវាយប្រហារប្រព័ន្ធប្រតិបត្តិការ **ថ.ផ.ឆ.** និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់សមាជិក និង
- ការវាយប្រហារផ្សេងៗទៀតដែលបង្កហានិភ័យដល់សន្តិសុខប្រព័ន្ធអន្តរប្រតិបត្តិការ **ថ.ផ.ឆ.**។

**មាត្រា២៣.-**

រាល់សមាជិក **ថ.ផ.ឆ.** ត្រូវមានវិធានការសន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរៀងៗខ្លួន ក្នុងការការពារ និងទប់ស្កាត់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតទៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន ដែលប៉ះពាល់ដល់ប្រក្រតីភាពនៃដំណើរការផ្លាស់ប្ដូរទិន្នន័យលើ **ថ.ផ.ឆ.** និងទិន្នន័យផ្ទាល់ខ្លួនរបស់ឯកជនដែលការពារដោយច្បាប់។

សមាជិក **ថ.ផ.ឆ.** ត្រូវរាយការណ៍ជូនប្រតិបត្តិករ **ថ.ផ.ឆ.** ពីហានិភ័យដែលអាចបង្កឡើង និង/ឬប៉ះពាល់ដល់សុវត្ថិភាព **ថ.ផ.ឆ.** និងត្រូវសហការជាមួយប្រតិបត្តិករ **ថ.ផ.ឆ.** ដើម្បីរកដំណោះស្រាយ។

**មាត្រា២៤.-**

ប្រតិបត្តិករ និងសមាជិក **ថ.ផ.ឆ.** ត្រូវរៀបចំឱ្យមានការត្រួតពិនិត្យវាយតម្លៃលើសន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ **ថ.ផ.ឆ.** តាមការចាំបាច់ ដោយស្ថាប័នជំនាញ។ ប្រតិបត្តិករ **ថ.ផ.ឆ.** មានកាតព្វកិច្ចអនុវត្តតាមរបាយការណ៍ត្រួតពិនិត្យវាយតម្លៃ និងធ្វើការជួសជុលចំណុចខ្វះខាតដែលអាចគំរាមកំហែងដល់សន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ **ថ.ផ.ឆ.**។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា២៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យលេខ ១៦៤ អនក្រ.បក**

**ស្តីពីការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា**

**ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២១**

## សន្ទានុក្រម

### ក

**កូដនីយកម្ម (Encryption)** សំដៅដល់ការបំប្លែងព័ត៌មាន ឬទិន្នន័យទៅជាកូដពិសេសណាមួយដែលគេមិនអាចយល់ ឬប្រើប្រាស់បាន។

**កំណត់ត្រាអេឡិចត្រូនិក (Timestamp)** សំដៅដល់កំណត់ត្រាដែលត្រូវបានបង្កើតឡើង ទាក់ទង ទទួល រក្សាទុក ឬដំណើរការក្នុងប្រព័ន្ធអេឡិចត្រូនិក ឬសម្រាប់បញ្ជូនពីប្រព័ន្ធអេឡិចត្រូនិកមួយទៅប្រព័ន្ធអេឡិចត្រូនិកមួយទៀត។

### ច

**ចំនួនប្រតិបត្តិការ (Number of transaction)** សំដៅដល់ចំនួននៃការស្នើសុំទិន្នន័យមកកាន់អ្នកផ្តល់ទិន្នន័យដែលមួយប្រតិបត្តិការត្រូវបានកំណត់យកនៅពេលដែលអ្នកផ្តល់ទិន្នន័យឆ្លើយតបទៅវិញដោយជោគជ័យតាមតម្រូវការនៃការស្នើសុំទិន្នន័យនោះ។

### ទ

**ទិន្នន័យគោល (Base registry)** សំដៅដល់ទិន្នន័យមូលដ្ឋានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចដែលជាម្ចាស់ទិន្នន័យដើម ហើយមានតែម្ចាស់ទិន្នន័យដើមទេដែលមានសិទ្ធិធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងនោះស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មានជាអាទិ៍ ទិន្នន័យអត្រានុកូលដ្ឋាន ទិន្នន័យបញ្ជាក់អត្តសញ្ញាណ (លិខិតឆ្លងដែន, បណ្ណបើកបរ, បណ្ណរបបសន្តិសុខសង្គម) ទិន្នន័យយានយន្ត ទិន្នន័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទិន្នន័យធុរកិច្ច ទិន្នន័យអចលនវត្ថុ ទិន្នន័យភូមិសាស្ត្រ ទិន្នន័យចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធ ទិន្នន័យអប់រំ ទិន្នន័យការងារ ទិន្នន័យធានារ៉ាប់រង ទិន្នន័យរបបសន្តិសុខសង្គម ទិន្នន័យសុខាភិបាល និងទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទិន្នន័យមូលដ្ឋាន (Database)** សំដៅដល់បណ្តុំនៃទំនាក់ទំនងទិន្នន័យ ឬព័ត៌មានដែលរក្សាទុកក្នុងកុំព្យូទ័រតាមវិធីណាមួយ ដោយក្នុងនោះ វាផ្តល់ភាពងាយស្រួលក្នុងការមើល បន្ថែម ស្វែងរក ឬធ្វើបច្ចុប្បន្នភាពទិន្នន័យ។

### ប

**បរិវត្តកម្មឌីជីថល (Digital transformation)** សំដៅដល់សមាហរណកម្មនៃបច្ចេកវិទ្យាឌីជីថល នៅក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពសេដ្ឋកិច្ច និងសង្គម ដើម្បីជំរុញប្រសិទ្ធភាពសេដ្ឋកិច្ច ទំនាក់ទំនងសង្គម និងផលិតភាពនៃប្រតិបត្តិការការងារ។

**ម**

**ម៉ាស៊ីនមេសុវត្ថិភាព (Security server)** សំដៅដល់ម៉ាស៊ីនមេដែលមានតួនាទីផ្ទៀងផ្ទាត់ការស្នើសុំឆ្លើយតប (request-response) របស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលធ្វើការផ្លាស់ប្ដូរទិន្នន័យប្រកបដោយសុវត្ថិភាព ហើយមានតួនាទីជាអ្នកធ្វើកូដនីយកម្ម និងវិកូដនីយកម្មលើទិន្នន័យ។

**ម្ចាស់ទិន្នន័យដើម (Original data owner)** សំដៅដល់ក្រសួង-ស្ថាប័នដែលមានសិទ្ធិអំណាចពេញលេញកាន់កាប់ទិន្នន័យជារបស់ខ្លួន និងដែលមានសមត្ថកិច្ចក្នុងការធ្វើបច្ចុប្បន្នភាពទិន្នន័យ។

**យ**

**យថាភូតភាព (Authenticity)** សំដៅដល់ការបញ្ជាក់អត្តសញ្ញាណអ្នកប្រើប្រាស់កុំព្យូទ័រក្នុងគោលបំណងសន្តិសុខ ដោយការផ្ទៀងផ្ទាត់ (ឈ្មោះ លេខសម្ងាត់ កាត ក្រយៅដៃ សំឡេង ភ្នែក មុខ ។ល។)។

**ស**

**សន្តិសុខបច្ចេកវិទ្យាព័ត៌មាន (Cyber security)** សំដៅដល់បច្ចេកវិទ្យាប្រឆាំងនឹងការប្រើប្រាស់ទិន្នន័យព័ត៌មានដោយគ្មានការអនុញ្ញាត។

**សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interface ឬហៅកាត់ថា API)** សំដៅដល់ច្រកចេញចូលស្តង់ដារដែលអនុញ្ញាតឱ្យទិន្នន័យអាចផ្លាស់ប្តូរពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយផ្សេងទៀត។ ការផ្លាស់ប្តូរទិន្នន័យ គឺតម្រូវឱ្យស្របតាមលក្ខខណ្ឌដែលបានកំណត់។

**ហ**

**ហត្ថលេខាឌីជីថល (Digital signature)** សំដៅដល់ទិន្នន័យដែលភ្ជាប់នឹងសារអេឡិចត្រូនិក ដើម្បីបញ្ជាក់អត្តសញ្ញាណនៃហត្ថលេខីឌីជីថល និងផ្ទៀងផ្ទាត់ស្ថានភាពដើមនៃសារអេឡិចត្រូនិក ដែលហត្ថលេខីឌីជីថលបានចុះហត្ថលេខា។

**ឧ**

**ឧក្រិដ្ឋកម្មឌីជីថល (Digital crime)** សំដៅដល់ការប្រព្រឹត្តអំពើល្មើសនានា តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

## ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យលេខ ១៦៤ អនក្រ.បក
## ស្តីពីការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
## ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២១

### គំនូសតាងប្រព័ន្ធអន្តរប្រតិបត្តិការ ថ.ផ.ទ.




(1) **សមាសភាគស្នូល** (Core Component) មានតួនាទីគ្រប់គ្រងម៉ាស៊ីនមេសុវត្ថិភាព និងគ្រប់គ្រងប្រតិបត្តិការទូទៅក្នុង **ថ.ផ.ទ.**។

(2) **ម៉ាស៊ីនមេសុវត្ថិភាព** (Security Server) មានតួនាទីជាច្រកចេញចូលនៃសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (API Gateway) និងជាអ្នកធានាសុវត្ថិភាពនិងសុចរិតភាពការផ្លាស់ប្តូរទិន្នន័យ តាមរយៈការធ្វើកូដនីយកម្ម ការចុះហត្ថលេខាឌីជីថល និងការធ្វើកំណត់ត្រាអេឡិចត្រូនិកនៃប្រតិបត្តិការផ្លាស់ប្តូរទិន្នន័យម្តងៗ។ ម៉ាស៊ីនមេសុវត្ថិភាព គឺជាសមាជិករបស់ **ថ.ផ.ទ.**។

(3) **ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្តល់ និងទទួលទិន្នន័យ** (Data Provider and Consumer) ជាអ្នកផ្តល់ និងទទួលទិន្នន័យ ដែលត្រូវតភ្ជាប់ជាមួយម៉ាស៊ីនមេសុវត្ថិភាព ដើម្បីធានាសុវត្ថិភាពនិងសុចរិតភាពទិន្នន័យពេលផ្លាស់-ប្តូរទិន្នន័យ។

(4) **សមាសភាគផ្តល់ទំនុកចិត្ត** (Trusted Component) ជាអ្នកគ្រប់គ្រងវិញ្ញាបនបត្រឌីជីថល (Digital Certificate) សម្រាប់ប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណសមាជិក និងធ្វើកូដនីយកម្ម/វិកូដនីយកម្មពេលផ្លាស់ប្តូរទិន្នន័យ និងជាអ្នកធ្វើកំណត់ត្រាអេឡិចត្រូនិកនៃរាល់ប្រតិបត្តិការផ្លាស់ប្តូរទិន្នន័យ។